ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តមណ្ឌលគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ ៨៤
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០
សាលក្រមព្រហ្មទណ្ឌ
លេខ ...៥៦../២១ "ឃ"
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង ជាប្រធានក្រុមប្រឹក្សា
លោក ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា
លោកស្រី ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៤ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ដែលប្តឹងមកតុលាការតាមដីកាដំណោះស្រាយលេខ ២៤៧៤/២០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

- ឈ្មោះ [redacted] **វឌ្ឍ** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នភូមិឆ្កែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ប្រពន្ធឈ្មោះ [redacted] សុភក្តិ ជា នីតិជន ទោសពីមុន "គ្មាន"។

ជាប់ចោទពីបទ៖ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិឆ្កែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៧ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។
- បានឃើញ ដីកាដំណោះស្រាយលេខ ២៤៧៤/២០ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០។
- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៣៨០ រប/២០ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។
- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ១៥/២០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។



Scanned with CamScanner

## អង្គហេតុដែលប្តឹងមកតុលាការ[១]

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៩និង០០នាទីយប់ ស្ថិតនៅភូមិឆ្អែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី មានករណីឃាតកម្មមួយបានកើតឡើង ដោយមានឈ្មោះ [redacted] ប៊ុន ឈ្មោះ [redacted] ផល ណាត ឈ្មោះ [redacted] សុខុម បាននាំគ្នាជិះម៉ូតូទៅមើលល្ខោន ហើយបាននាំគ្នាផឹកស្រាអស់ពីរដប រួចក៏ឈ្លោះគ្នាប្រតាយប្រតប់គ្នាជាមួយឈ្មោះ ប្រងើយ ដែលមានគ្នាចំនួន ០៤នាក់។ ក្រោយមកមានការឈ្លោះគ្នាម្តងទៀតជាមួយឈ្មោះ [redacted] ផល្លា ដដែល។ ក្រោយពីបានឈ្លោះគ្នាចំនួន ០២លើករួចមក ឈ្មោះ [redacted] ប៊ុន និងឈ្មោះ [redacted] សុខុម បានចេញពីរោងល្ខោន ធ្វើដំណើរត្រឡប់ទៅវិញ ស្រាប់តែឈ្មោះ [redacted] វង្ស បានចាំស្ទាក់ ហើយបានយកដំបងវាយទៅលើឈ្មោះ [redacted] សុខុម រហូតដល់ស្លាប់ ហើយរត់គេចខ្លួនបាត់។

## នាពេលសវនាការ

- អំណានចម្លើយសាក្សីឈ្មោះ [redacted] វ៉ុន បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៩យប់ ខ្លួនមានគ្នា ០៤នាក់ រួមមាន៖ ឈ្មោះ ប៊ុន ឈ្មោះ ណាត ឈ្មោះ វ៉ុន និងឈ្មោះ ខុម (ជនរងគ្រោះ) បាននាំគ្នាជិះម៉ូតូមកមើលល្ខោននៅភូមិឆ្អែង ដោយពួកខ្លួនស្រវឹងទាំងអស់គ្នា។ ពេលទៅដល់រោងល្ខោនពួកខ្លួនដើរលេងមួយស្របក់ ក៏នាំគ្នាទៅផឹកស្រាអស់ចំនួន ០២ដប ក្រោយមកពួកខ្លួនបានចេញពីកន្លែងផឹកមកមើលគេលេងល្ខោន ក៏បានជួបនឹងអាងើយ ហើយពួកវាមានគ្នា០៤នាក់ តែខ្លួនមិនស្គាល់អាបីនាក់នោះទេ ពេលនោះអាងើយបានវាយក្បាលរបស់ខ្លួនខ្លាំងៗ ខ្លួនខឹងពេកក៏ឈ្លោះគ្នា និងប្រតាយប្រតប់ជាមួយអាងើយ ហើយពួកម៉ាកខ្លួនឈ្មោះ ប៊ុន និងឈ្មោះ ណាត បានចាប់ខ្លួនចេញ រួចបែកគ្នាទៅ។ ចំណែកខ្លួននិងពួកម៉ាកខ្លួន ដើរលេងបែកគ្នាទាំងអស់ ខ្លួនដើរតែម្នាក់ឯងទេ។ ពេលខ្លួនដើរចេញពីវង់ល្ខោន បានប្រហែល ៥ម៉ែត្រ ស្រាប់តែជួបនឹងក្រុមអាងើយទៀត តែមានគ្នា០២នាក់ទេ ហើយខ្លួន និងអាងើយបានប្រកែកគ្នាទៀត តែត្រូវឈ្មោះ ណាត និងឈ្មោះ ប៊ុន បានចាប់ខ្លួនចេញ ស្រាប់តែអាម្នាក់ខ្ពស់ដែលដើរជាមួយអាងើយនោះ បានមកវាយឈ្មោះ ណាត មួយដៃ ចំណែកឯឈ្មោះ ខុម (ជនរងគ្រោះ) មិនដឹងនៅកន្លែងណាទេ ហើយពួកខ្លួននាំគ្នាមកលេងនៅខាងក្នុងវង់ល្ខោនវិញ ក៏ត្រូវប៉ូលីសឈ្មោះ សឹង បានដេញខ្លួនឲ្យត្រឡប់ទៅផ្ទះ រួចពួកខ្លួនបានដើររកគ្នា ពេលជួបគ្នាទាំងបួននាក់ហើយ ក៏នាំគ្នាមកផ្ទះ។ ពេលនោះឈ្មោះ ខុម ជាអ្នកធាក់ម៉ូតូតែមិនឆេះ ឈ្មោះ ខុម បានឲ្យឈ្មោះ ប៊ុន ជាអ្នករុញម៉ូតូចេញមកក្រៅ ហើយឈ្មោះ ខុម ជាអ្នកជិះ។ ចំណែកខ្លួន និងឈ្មោះ ណាត បានទៅទិញទឹកផឹក រួចនៅដើរលេងមួយស្របក់ទៀត ស្រាប់តែគេផ្អើលឈ្លោះ។ ខ្លួន និងឈ្មោះ ណាត បានដើរមកមើល ស្រាប់តែឃើញម៉ូតូដួល និងឈ្មោះ ខុម (ជនរងគ្រោះ) ដេកនៅផ្លូវថ្នល់ ហើយមិនឃើញឈ្មោះ ប៊ុន ទេ។ ពេលនោះឈ្មោះ ណាត បានលើកបីឈ្មោះ ខុម ដាក់លើឡានឈ្មោះ ភក្ត្រ ដឹកមកផ្ទះបងប្អូន រួចម្តាយជនរងគ្រោះបានយកមកមណ្ឌលសុខភាព ចំណែកខ្លួនមិនបានមកទេ គឺដេកនៅផ្ទះ ទាល់តែព្រឹកឡើងទើបខ្លួន

---

[១] មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ



Scanned with CamScanner

ដឹងថាឈ្មោះ ខុម ស្លាប់។ រួចខ្លួនបានងូងទឹក ហើយមកមណ្ឌលសុខភាពឃើញឈ្មោះ ខុម ស្លាប់ពិតមែន។ តែមិនដឹងថានរណាជាអ្នកសម្លាប់ទេ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ណាត បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ មុនដំបូងខ្លួននាំគ្នាបួននាក់ទៅមើលល្ខោននៅសាលារៀនភូមិឆ្អែង ១ឈ្មោះ វ៉ុន ២ឈ្មោះ ប៊ុន ៣ឈ្មោះ ខុម ។ ពេលទៅដល់កន្លែងរោងល្ខោន ខ្លួនបានចូលផឹកស្រាជាមួយឈ្មោះ ប្រងើយ គ្នារបស់ខ្លួនមានបីនាក់ ឯឈ្មោះ ប៊ុន មិនបានចូលរួមផឹកស្រាជាមួយនោះទេ ឯក្រុមអាប្រងើយ មានគ្នាចំនួន០៤នាក់ អ្នកទាំងនោះខ្លួនមិនបានស្គាល់ទេ។ ពេលក្រោយមកឈ្មោះប្រងើយ និងឈ្មោះ វ៉ុន បានយកដៃវាយក្បាលគ្នាទៅវិញទៅមក ហើយក៏លើកដបគំរាមរកវាយគ្នាទៅវិញទៅមក ពេលនោះឈ្មោះ វ៉ុន ត្រូវជាប្អូនជីដូនមួយខ្លួន ក៏ចេញមកក្រៅរោងល្ខោន ហើយឃើញប្រកែកគ្នាជាមួយឈ្មោះ ប្រងើយ។ ពេលនោះខ្លួនក៏ទៅទាញឈ្មោះ វ៉ុន ចេញមក តែវាមិនព្រមមក ខ្លួនក៏ទះមួយកំភ្លៀង ពេលនោះខ្លួនក៏ដើរឃាត់អាប្រងើយ ត្រូវពួកអាប្រងើយវាយខ្លួនមួយដៃចំភ្នែកខាងឆ្វេង។ ក្រោយមកក៏បែកគ្នា ឯពួកខ្លួនក៏ទាញម៉ូតូមកផ្ទះ តែម៉ូតូអត់ឆេះក៏នាំគ្នារុញម៉ូតូទៅតែមិនឆេះ ខ្លួនក៏ចូលទិញទឹក ឲ្យឈ្មោះ ប៊ុន និងឈ្មោះ ខុម រុញម៉ូតូបញ្ឆេះ។ ពេលដែលខ្លួនចេញពីកន្លែងទិញទឹកទៅវិញ ក៏ឮសូរថា គេវាយពីណាដួលម៉ូតូច្រងាង។ ពេលនោះមានភ្លើងឡានមកពីទិសខាងកើត ខ្លួនក៏ទៅមើលឃើញម៉ូតូដួល និងមនុស្សដេកនៅនឹងដី។ ពេលនោះខ្លួនក៏រត់ទៅដល់កន្លែងនោះ ហើយក៏លើកគ្នាខ្ញុំឡើង ពេលនោះឡានរបស់ឈ្មោះ ភក្រ្ត ក៏បើកទៅឈប់កន្លែងនោះដែរ។ ពេលនោះខ្លួនក៏ពឹងឈ្មោះ ភក្រ្ត ឲ្យជួយដឹកមកពេទ្យ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ប៊ុន បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៥និង៣០នាទីល្ងាច ខ្លួនមកពីចំការ ងូតទឹករួចខ្លួនដើរទៅលេងផ្ទះឈ្មោះ ណាត ក៏បានឃើញគេកំពុងផឹកស្រា។ ឈ្មោះ ណាត បានហៅខ្លួនចូលផឹក ដោយមានគ្នា ០៨នាក់។ ខ្លួនផឹកស្រាសអស់០២កាដុង ស្មើនឹង ៤លីត្រ។ រហូតដល់ម៉ោង ៧និង៣០នាទីយប់ ពួកខ្លួនក៏បបួលគ្នាទៅមើលល្ខោននៅសាលារៀនភូមិឆ្អែង មានគ្នា០៤នាក់ គឺឈ្មោះ ណាត ឈ្មោះ ខុម (ស្លាប់) ឈ្មោះ វ៉ុន ជិះម៉ូតូ០១គ្រឿង មានគ្នា០៤នាក់។ ពេលទៅដល់រោងល្ខោន ក៏ទិញសំបុត្រចូលមើល ហើយចូលដល់ក្នុងពួកខ្លួនក៏ដើរបែកគ្នា។ មួយសន្ទុះធំ ពេលខ្លួនទៅជុះនោមក្រោយរោងល្ខោន បានឃើញឈ្មោះ ណាត ឈ្មោះ ខុម និងឈ្មោះ វ៉ុន ផឹកជាមួយក្រុមរបស់ឈ្មោះ ព្រងើយ ហើយឈ្មោះ ណាត ក៏ហៅខ្លួនចូលផឹក។ ពេលនោះខ្លួនចូលផឹកអស់ស្រា ០១ដប ស្រាប់តែឈ្មោះ ព្រងើយ និងឈ្មោះ វ៉ុន បានប្រកែកគ្នា រកវាយគ្នា ពួកខ្លួនដែលផឹកជាមួយគ្នាបានឃាត់មិនឲ្យឈ្លោះគ្នា ពេលនោះឈ្មោះ ព្រងើយ និងពួកម៉ាកវាម្នាក់ ខ្លួនមិនស្គាល់ឈ្មោះ មានរាងខ្ពស់ស្គម ពាក់អាវយឺតដៃខ្លី ពណ៌ក្រហម ដើរចេញទៅបាត់។ រហូតដល់ល្ខោនចប់ ពួកខ្លួនទាំង០៤នាក់ បានដើរចេញ បំរុងត្រឡប់ទៅផ្ទះ ពេលដើរចេញដល់មុខរោងល្ខោនខាងក្រៅ ខ្លួនឃើញឈ្មោះ ព្រងើយ ប្រកែកគ្នាជាមួយឈ្មោះ វ៉ុន ម្តងទៀត មានគ្នាច្រើននាក់។ ពេលគេកំពុងប្រកែកគ្នា ឈ្មោះ ខុម ក៏បានទៅយកម៉ូតូចេញមកមុខរោងល្ខោន។ មួយសន្ទុះ ឈ្មោះ ខុម ហៅខ្លួនទៅកន្លែងម៉ូតូ ខ្លួនបានឲ្យឈ្មោះ ខុម ធាក់ម៉ូតូ ខ្លួនមើលភ្លើងប៊ូស្សី។ ពេលធាក់មិនឆេះឈ្មោះ

ខុម បានឲ្យខ្លួនឡើងជិះ ហើយឈ្មោះ ខុម ជាអ្នករុញ។ លើកទី១ បានចំងាយប្រហែល ៥០ម៉ែត្រ មិនឆេះ រួចក៏រុញលើកទី២ បានចំងាយ ៥០ម៉ែត្រទៀតក៏នៅតែមិនឆេះ ខ្លួនក៏ចុះមើលភ្លើងប៊ូស្សីទៀត ដោយឲ្យឈ្មោះ ខុម អ្នកផាក់។ មួយសន្ទុះខ្លួនឃើញវាហាត់ ខ្លួនក៏ឡើងផាក់ម្តង គ្រាន់តែខ្លួនឡើងឈរ ក៏ក្រឡេកឃើញមនុស្ស ០៣នាក់ ស្គមៗ រាងខ្ពស់ជាខ្លួន បានរត់សំដៅមកពួកខ្លួននៅកន្លែងម៉ូតូ ដោយមានកាន់ដំបងមកជាមួយ។ ខ្លួនឃើញក៏ស្រែកថា អាខុមរត់ រួចរូបខ្លួនក៏រត់មុន ចុះថ្នល់ចូលព្រៃ ហើយខ្លួនក៏ដួល។ ក្រោយមកខ្លួនក៏ចេញពីព្រៃវិញដើរឡើងមកថ្នល់ ក៏ឃើញឡានពូភក្រ្ត ខ្លួនក៏ដើរសំដៅមកឡាន។ ពេលមកដល់ខ្លួនឃើញឈ្មោះ ខុម និងឈ្មោះ វ៉ុន ដេកនៅលើឡាន មានម៉ូតូ០១គ្រឿង ខ្លួនក៏ជិះឡានមកពេទ្យ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ផល្លា ហៅព្រងើយ ភេទប្រុស អាយុ២១ឆ្នាំ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ១០ព្រឹក ខ្លួនបានជិះម៉ូតូទៅលេងជាមួយមិត្តភក្តិឈ្មោះ នូ ផលណាត នៅកន្លែងលេងល្បែង សាលារៀនភូមិឆ្អែង ជាអ្នកចាក់ឌីសឲ្យវង់ល្បែង។ ពេលខ្លួនទៅដល់ក៏បានបបួលគ្នាផឹកនៅក្នុងរោងល្ខោន មានគ្នា ០៤នាក់ ជាមួយអ្នកលេងល្ខោន ផឹកអស់ស្រាពពែមាសចំនួន ០៤ដប ដល់ម៉ោង ២រសៀលក៏នាំគ្នាឈប់ ហើយដេករហូតដល់ម៉ោង ៥និង៣០នាទី ល្ងាច ខ្លួនងើបទៅងូតទឹក រួចដល់ម៉ោង ៦ល្ងាច ខ្លួននៅចាក់ឌីសជាមួយឈ្មោះ [redacted] ផលណាត រហូតដល់ម៉ោង ៩យប់ ខ្លួនបានឃើញក្រុមរបស់អាណាត (ជុំ ណាត) មានគ្នា ០៤នាក់ គឺឈ្មោះ ណាត ឈ្មោះ វ៉ុន និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ បានទៅបបួលខ្លួនផឹកនៅជាប់កន្លែងចាក់ឌីស មានគ្នាទាំងអស់ ០៧នាក់។ ខ្លួនផឹកជាមួយអស់ស្រាផែនដី ០៣ដប និងស្រាដំណើបខ្មៅ ០២ដប រួចខ្លួនក៏ប្រកែកគ្នាជាមួយឈ្មោះ វ៉ុន ហើយអ្នកផឹកជាមួយក៏បានឃាត់។ ខ្ញុំឈប់ផឹក ហើយងើបចេញ រហូតដល់ល្ខោនចប់ ពូភក្រ្ត បានហៅខ្លួនទៅផ្ទះ។ ពេលនោះខ្លួនចេញមកក្រៅ ឡើងឡានបំរ៉ុងមកផ្ទះ ស្រាប់តែឃើញអាណាត វាយអាវ៉ុន ដួល ខ្លួនក៏ចុះពីលើឡានទៅឃាត់ ហើយឡានពូភក្រ្តក៏បើកចេញទៅផ្ទះបាត់។ ពេលខ្លួនចូលឃាត់ ឈ្មោះ វ៉ុន បានវាយខ្លួនមួយដៃ ត្រូវបំពង់ក ហើយខ្លួនក៏វាយតវិញចំនួន ០៣ដៃ និងចាប់បោកវាទៅនឹងដី រួចឈ្មោះ [redacted] ផលណាត បានមកចាប់ទាញខ្លួនចេញ។ នៅពេលខ្លួនវាយគ្នាជាមួយឈ្មោះ វ៉ុន មានគេឈរមើលច្រើន ហើយនៅពេលនោះខ្លួននៅឈរមុខរោងល្ខោន បានឃើញឈ្មោះ ណាត និងឈ្មោះ វ៉ុន លោតទៅវាយឈ្មោះ រដ្ឋ រួចឈ្មោះ រដ្ឋ ក៏បានវាយឈ្មោះ ណាត និងឈ្មោះ វ៉ុន ដួលទាំងពីរនាក់។ បន្ទាប់មកពូសឹង (ប៉ូលីស) ក៏បានមកឃាត់បំបែក ហើយពូសឹងក៏បានដេញបក្ខពួករបស់ឈ្មោះ ណាត ឲ្យទៅផ្ទះ ខ្លួនក៏ឈរនៅមុខរោងល្ខោនជាមួយឈ្មោះ ផលណាត ពូសឹង និងពូសត់ បានប្រហែល ១០នាទី ឡានពូភក្រ្តក៏ត្រឡប់មកវិញ ក៏បានឃើញម៉ូតូដួលនៅគៀនផ្លូវ ហើយប្រាប់ពួកខ្លួននាំគ្នាទៅមើល ក៏ឃើញឈ្មោះ វ៉ុន និងឈ្មោះ ខុម ដេកនៅក្បែរគ្នា ក៏យកឡើងឡានមកពេទ្យ។ -

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ផលណាត ភេទប្រុស អាយុ២៥ឆ្នាំ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៧ព្រឹក ឈ្មោះ [redacted] ផល្លា បានមកលេងនៅរោងល្ខោន ដោយជិះម៉ូតូតែម្នាក់ឯង។ រហូតដល់ពេលថ្ងៃហូបបាយជាមួយខ្លួន លុះដល់ពេលយប់វេលា

ម៉ោង ៧និង៣០នាទី យប់ទើបក្រុមល្ខោនចាប់ផ្ដើមលេង។ ខ្លួន និងឈ្មោះ [redacted] ផល្លា ហៅចាក់ឌីសនៅក្បែររោងល្ខោន វេលាម៉ោងប្រហែល ៩និង៣០នាទីយប់ គ្នារបស់ឈ្មោះ [redacted] ផល្លា បានមកកន្លែងខ្លួនចាក់ឌីសមានគ្នា ០៥នាក់ សុទ្ធតែប្រុសៗ ខ្លួនមិនស្គាល់ឈ្មោះទេ ថែមទាំងកាន់ដបស្រាផែនដីពីរដប និងមានសាច់ក្លែមក៏នាំគ្នាផឹកស៊ីអស់ចំនួន មួយដបកន្លះ ក៏ចាប់ផ្ដើមវាយក្បាលគ្នាលេង ដោយមានភាពស្រវឹង ខ្លួនកំពុងចាក់ឌីសឮសម្លេងប្រកែកគ្នាឈ្មោះ វ៉ុន និងឈ្មោះ ផល្លា។ ផល្លានិយាយថា អញវាយក្បាលអាស្អែងលេងមិនបានអាពួកម៉ាក? ឈ្មោះ វ៉ុន ក៏និយាយអញ្ចឹងដែរឬ ហើយខ្លួនក៏ហៅឈ្មោះ ផល្លា ទៅហូបប្រហិត និងផឹកស្រាបៀរអាន់ឆ័រអស់ម្នាក់មួយកំប៉ុង ស្រាប់តែពូរបស់ផល្លា ឈ្មោះ ភ័ក្រ ដើរកាត់ ហៅឈ្មោះ ផល្លា ទៅផ្ទះនៅម៉ោងប្រហែល ១០យប់។ លុះម៉ោង ១០និង៣០នាទី ខ្លួនក៏បានទូរស័ព្ទសួរផល្លាថា អាស្អែងដល់ផ្ទះហើយឬនៅ? ផល្លាឆ្លើយថា វាមានរឿងនៅខាងក្រៅ ខ្លួនក៏ចេញទៅមើលរឿងនោះចប់អស់ហើយ។ សមត្ថកិច្ចនគរបាលនៅទីនោះ ឈ្មោះ ផល្លា និងឈ្មោះ វ៉ុន បក្ខពួកបួននាក់ទៀតនៅទីនោះដែរ។ ឈ្មោះ ផល្លា បាននិយាយប្រាប់ខ្លួនថា ឈ្មោះ វ៉ុន វាយវាត្រូវបំពង់ក ខ្លួនក៏ហៅផល្លា ទៅក្នុងរោងល្ខោនលាបប្រេងកូឡា តែមិនទាន់ដល់រោងផង មានក្មេងប្រុសម្នាក់ស្រែកប្រាប់គ្នាជនរងគ្រោះថា មានគេវាយគ្នាគាត់ហើយ ពួកវាក៏រត់ទៅកន្លែងជនរងគ្រោះ។ ពូរបស់ផល្លា ឈ្មោះ ភ័ក្រ បានហៅផល្លា ឡើងឡាន ជួយលើកជនរងគ្រោះដឹកទៅពេទ្យ ផល្លា ក៏បានហៅខ្លួនទៅដែរ។ ពេលដល់កន្លែងកើតហេតុខ្លួនក៏ចុះពីលើឡានជាមួយផល្លា គ្នារបស់ជនរងគ្រោះលើកជនរងគ្រោះដាក់លើឡានរបស់ពូភ័ក្រ ហើយក៏បើកទៅពេទ្យ ចំណែកខ្លួន និងឈ្មោះ ផល្លា បានដើរមកកន្លែងរោងល្ខោនមកដេក។ នៅយប់នោះ វេលាម៉ោងប្រហែល ៣និង៣០នាទីយប់ មិនដឹងផល្លាទៅណា លុះវេលាម៉ោងជិត៤ភ្លឺ សមត្ថកិច្ចក៏មកហៅខ្លួនទៅកន្លែងប៉ុស្តិ៍សាកសួរបំភ្លឺ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] សុភក្តិ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ កាលពីថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៧យប់ ប្ដីរបស់ខ្លួនឈ្មោះ [redacted] វង្ស បានចេញពីផ្ទះទៅមើលល្ខោន តែខ្លួនមិនបានឃើញឈ្មោះ [redacted] វង្ស ត្រឡប់មកផ្ទះវិញទេ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

- ក្រោយពីស្ដាប់អំណានចម្លើយសាក្សីរួចមក តំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

- កូនក្ដីរបស់ខ្លួនគ្មានទោសទេ ដោយសារតែមិនមានភស្តុតាង និងសាក្សីគ្រប់គ្រាន់ច្បាស់លាស់ ជាពិសេសសាក្សីមានវិមតិសង្ស័យ។ ខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ និងសម្រេចឲ្យកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វង្ស បានរួចផុតពីបទចោទប្រកាន់ ដើម្បីមានសេរីភាពដូចប្រជាពលរដ្ឋដទៃ ស្របតាមមាត្រា៣៨ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣៥០។



Scanned with CamScanner

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ គ្មាន (ជនជាប់ចោទអវត្តមាន)
- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ។

## សំអាងហេតុ

១. កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨និង០០នាទីយប់ ស្ថិតនៅភូមិឆ្អែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ពិតជាមានអង្គហេតុនៃបទល្មើស ឃាតកម្ម កើតឡើងប្រាកដមែន។ មុនពេលកើតហេតុ ឈ្មោះ [redacted] ប៊ុន ឈ្មោះ[redacted]ណាត ឈ្មោះ [redacted]វ៉ុន និងឈ្មោះ [redacted]សុខុម បាននាំគ្នាជិះម៉ូតូទៅមើលល្ខោននៅចំណុចខាងលើ ហើយបានឈ្លោះគ្នាជាមួយក្រុមម្ខាងទៀតមានឈ្មោះ [redacted] ផល្លា ហៅប្រងើយ ឈ្មោះ [redacted] ផលណាត និងឈ្មោះ [redacted]រដ្ឋ ចំនួន ០២លើក។ ពេលល្ខោនចប់ ឈ្មោះ [redacted] ប៊ុន ឈ្មោះ [redacted]ណាត ឈ្មោះ[redacted] វ៉ុន និងឈ្មោះ[redacted]សុខុម បាននាំគ្នាត្រឡប់មកផ្ទះ ប៉ុន្តែដោយធាក់ម៉ូតូមិនឆេះ ទើបឈ្មោះ [redacted] ប៊ុន និងឈ្មោះ [redacted] សុខុម នាំគ្នារុញម៉ូតូបញ្ឆេះ បានចម្ងាយប្រហែល ១០០ម៉ែត្រ ពីរោងល្ខោន ស្រាប់តែមានមនុស្សមួយក្រុមមានគ្នា ០៣នាក់ មកវាយឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] ប៊ុន ប៉ុន្តែដោយឈ្មោះ [redacted] ប៊ុន ឃើញជាមុនទើបរត់គេចខ្លួនចូលព្រៃ។ មួយសន្ទុះក្រោយមក មានគេឃើញឈ្មោះ [redacted] សុខុម ដេកនៅលើដី ហើយស្លាប់ក្រោយពេលបញ្ជូនដល់មន្ទីរពេទ្យ។

២. តាមរបាយការណ៍លេខ ០៦/២០១០ របក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី បានសន្និដ្ឋានថា៖ ឈ្មោះ [redacted]រដ្ឋ ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិជ្រោយស្តៅ ឃុំជ្រោយស្តៅ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ក្រោយពីបានឈ្លោះប្រកែកវាយតប់គ្នាចំនួន ០២លើក រវាងក្រុមរបស់ខ្លួន ដែលមានឈ្មោះ ១[redacted]ផលណាត ២.[redacted] ផល្លា និងក្រុមម្ខាងទៀត ១.ឈ្មោះ [redacted] សុខុម (ជនរងគ្រោះ) ២.ឈ្មោះ[redacted] ប៊ុន ៣.ឈ្មោះ [redacted]វ៉ុន ៤.ឈ្មោះ [redacted] ណាត រួចមក នៅពេលដែលជនរងគ្រោះឈ្មោះ [redacted] ប៊ុន និងឈ្មោះ [redacted] សុខុម ចេញពីរោងល្ខោនធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ឈ្មោះ [redacted]រដ្ឋ ក៏បានចាំស្ទាក់ ហើយយកដំបងវាយទៅលើឈ្មោះ [redacted]សុខុម រហូតដល់ស្លាប់ ហើយក៏បានរត់គេចខ្លួន ពិតប្រាកដមែន។

៣. តាមចម្លើយសាក្សីឈ្មោះ [redacted]សុភក្តិ បានឆ្លើយថា កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៧ យប់ ប្តីរបស់ខ្លួនឈ្មោះ ឆាង រដ្ឋ បានចេញពីផ្ទះទៅមើលល្ខោន តែខ្លួនមិនបានឃើញឈ្មោះ [redacted] រដ្ឋ ត្រឡប់មកផ្ទះវិញទេ។ ផ្អែកតាមចម្លើយនេះឃើញថា ជនជាប់ចោទពិតជាមានវត្តមាននៅកន្លែងកើតហេតុ ប៉ុន្តែក្រោយពេលកើតហេតុ ក៏បានរត់គេចខ្លួនពីមូលដ្ឋាន ដែលអាចបញ្ជាក់ថា ជនជាប់ចោទមានចេតនារត់គេចពីការទទួលខុសត្រូវ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។



Scanned with CamScanner

៤. អំពើរបស់ជនជាប់ចោទ ដែលបានសម្លាប់ជនរងគ្រោះ ដោយគ្មានស្ថានទម្ងន់ទោសណាមួយ គឺជាអំពើឃាតកម្ម តាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ហើយអំពើនេះស្តែងឱ្យឃើញនូវចេតនាទុច្ចរិតក្នុងការដកហូតយកអាយុជីវិតមនុស្ស និងបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គមទៀតផង។

៥. ជនជាប់ចោទ ជានីតិជន មាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានបញ្ហាវិកលស្មារតី ក្នុងពេលប្រព្រឹត្តល្មើសឡើយ។ ជនជាប់ចោទជាសមត្ថជនដែលមានការពិចារណា ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

៦. តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។ ការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវដែលអាចឱ្យតុលាការពិចារណាតាមច្បាប់។

៧. ចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ ដោយសារតែមិនមានភស្តុតាង និងសាក្សីគ្រប់គ្រាន់ច្បាស់លាស់ ជាពិសេសសាក្សីមានវិមតិសង្ស័យ។ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ពុំត្រឹមត្រូវឡើយ ដោយហេតុថា របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌បានសន្និដ្ឋានយ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] វណ្ណ បានយកដំបងវាយទៅលើឈ្មោះ [redacted] សុខុម រហូតដល់ស្លាប់ ហើយក៏បានរត់គេចខ្លួន។ អនុលោមតាមមាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឯកសារនេះត្រូវទុកជាបន្ទាល់ "ឯកសារដើម" ហើយត្រូវទុកជាឯកសារដែលត្រូវជឿ រហូតដល់មានភស្តុតាងផ្ទុយ។ ម្យ៉ាងទៀត ជនជាប់ចោទបានរត់គេចខ្លួនដោយមិនបានបង្ហាញភស្តុតាងផ្ទុយឡើយ។

៨. មានធាតុផ្សំបទល្មើស និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិឆ្នែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

៩. ជនជាប់ចោទ បានរត់គេចខ្លួនក្រោយពេលប្រព្រឹត្តបទល្មើសរួច ហើយអំពើរបស់ជនជាប់ចោទជាបទល្មើសឧក្រិដ្ឋ ដែលត្រូវដាក់ពន្ធនាគារលើសពី ១(មួយ)ឆ្នាំ ដែលអាចឱ្យតុលាការសម្រេចបង្គាប់ឱ្យចាប់ខ្លួន ជន-ជាប់ចោទ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០. តាមឯកសារភស្តុតាងក្នុងសំណុំរឿង ក្រុមប្រឹក្សាពិនិត្យឃើញថា ពុំមានសិទ្ធិវ័ន្តនៃជនរងគ្រោះ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ ដូច្នេះតុលាការពុំអាចវិនិច្ឆ័យអំពីសំណងផ្នែករដ្ឋប្បវេណីឡើយ។ ប៉ុន្តែសិទ្ធិវ័ន្តនៃជនរងគ្រោះ នៅតែមានសិទ្ធិប្តឹងទាមទារឱ្យជួសជុលព្យសនកម្ម តាមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមច្បាប់។



Scanned with CamScanner

## សេចក្ដីសម្រេច

១. ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ ដាក់ពន្ធនាគាររយៈពេល ១០(ដប់) ឆ្នាំ ពីបទ៖ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិឆ្នែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

២. ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណខាងលើ) តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ។

ភាគីមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ១២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

មណ្ឌលគិរី,ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២១

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner